អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងបែងចែកប្រភេទសំរាម**

**ចិត្តចលភាព** ៖ បំណិនចលនាធំ៖ ការហ្វឹកហាត់បង្កើតកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំតូច និងសាច់ដុំធំ

ការរីកចម្រើនរាងកាយនិងចលនា៖

ការបង្កើនកម្លាំងនិងការប្រឈមទប់ទល់នឹងឧបសគ្គពេលធ្វើសកម្មភាពផ្សេងៗ

**វិទ្យាសាស្ត្រ** ៖ បំណិនអនាម័យ៖ ទម្លាប់រស់នៅមានអនាម័យក្នុងគ្រួសារនិងសង្គម

**សិក្សាសង្គម** ៖ បំណិនក្នុងសង្គម៖ ការយល់ដឹងអំពីបរិស្ថានធម្មជាតិនិងវិធីការពារ

**បុរេគណិត** ៖ បរិមាណនិងចំនួន៖ ស្គាល់នឹងយល់លេខតាងនិងការគណនាលេខសាមញ្ញ

ទំហំនិងពណ៌៖ ចំណាត់ថ្នាក់ក្រុមនិងលំដាប់លំដោយ៖

**ភាសាខ្មែរ** ៖ ការប្រើពាក្យតាមវេយ្យករណ៍៖ ការយល់ពីវាក្យស័ព្ទ ឃ្លា និងល្បះ

**គោលបំណង**

**ចិត្តចលភាព** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីរបៀបវិធីដើរ រត់ លូន វារ លោត ចុះនិងឡើង បោះ តោង ទ្បើង គប់ ប្រមៀល រុញ និងទាញ ទៅតាមគោលដៅនិងចម្ងាយដែលបានកំណត់។

**វិជ្ជាសម្បទា**៖អនុវត្តសកម្មភាពមួយឱ្យបានទន់ភ្លន់រហ័សរហួននិងរឹងមាំដោយការចាប់ផ្តើមចេញពីចលនា

មូលដ្ឋានងាយៗទៅលំបាក ចំនួនពីរឡើងទៅក្នុងនោះមានការដើរ
រត់ លោតឬលើសពីនោះ តាមរយៈចលនាចរន្ត ហាត់ប្រាណតាមរឿងនិទាន បទចម្រៀង បទភ្លេង
និងល្បែងចលនា។

៖ បំណិនសម្បទា៖ ចោលសំរាមនៅក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ

**សិក្សាសង្គម** ៖ បំណិនសម្បទា៖ ជួយសម្អាតបរិស្ថាន ដូចជាការបោសសំរាម
និងមិនបន្ទោរបង់ផ្ដេសផ្ដាសជាដើម។

**បុរេគណិត** ៖ បំណិនសម្បទា៖ រាប់ចំនួនលេខ និងយល់ន័យពី១ដល់៣០ឬលើសពីនេះ។
បំណិនសម្បទា៖ រៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**ភាសាខ្មែរ** ៖ វិជ្ជាសម្បទា៖ ប្រាប់ពីពាក្យ ឃ្លា ឬល្បះ ឱ្យបានត្រឹមត្រូវទៅតាមស្ថានភាព
មនុស្សធំដែលមានចំនួនពី៥ទៅ៦ព្យាង្គឬលើសពីនេះ។

**កម្រិតសិក្សា** ៖ទាប មធ្យមនិង ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាតធុងសំរាមដែលមាន៤ឬ៥ ដែលមានពណ៌សម្គាល់ដែរ។ (ប្រភេទសំរាមមាន៖១. ពណ៌ស្វាយសំណល់ក្រដាស ២. ពណ៌ខៀវសំណល់កំប៉ុង ៣.ពណ៌បៃតងសំណល់ផ្ទះបាយ ៤. ពណ៌លឿងសំណល់ប្លាស្ទីក និង ៥. ពណ៌ក្រហមសំណល់គ្រោះថ្នាក់ ) ជាទំហំA4 (ពណ៌ / សខ្មៅ) បិទជាប់ជាមួយនឹងកន្ត្រកដែលតំណាងឱ្យធុងសំរាមពិត។ សំរាមដែលបានរៀបចំដូចជា៖ ក្រដាសដែលគេប្រើរួចក្លាយជាសំរាម កំប៉ុង ក្រដាសកេស កាកសំណល់ផ្សេងពីអាហារ សំរាមដែលមានគ្រោះថ្នាក់មួយចំនួន ថង់ ថប់ប្លាស្ទីកជាដើម។ បញ្ជាក់ មានកាន់តែច្រើនកាន់តែល្អ។

**ការរៀបចំ** ៖ ត្រៀមសម្ភារ ដូចជាកាតធុងសំរាមឬកន្ត្រកសំរាមពិត៤ឬ៥ឱ្យបានរួចរាល់ និងសម្ភារផ្សេងទៀតឱ្យគ្រប់គឺការស្រេច។

**សេចក្ដីណែនាំ** ៖

1. គ្រូសួរកុមារ តើកូនៗស្គាល់សំរាមដែរឬទេ? សំរាមមានប៉ុន្មានប្រភេទ?
2. បើពួកគេមិនទាន់ស្គាល់ទេ អាចប្រាប់ និងបង្ហាញពីប្រភេទសំរាមខ្លះទៅកាន់ពួកគេ ឱ្យបានយល់និងស្គាល់ឱ្យច្បាស់ជាមុនសិន មុននឹងលេងល្បែងនេះ ទើបមិនពិបាកលេង។
3. ប្រាប់កុមារពីរបៀបលេងល្បែងសកម្មភាពមួយជាមុនសិន

- ☐ ល្បែងនេះលេងជាក្រុម ដែលគ្រូអាចចែកសិស្សជា២ក្រុមក្នុង១ថ្នាក់ និងមានការប្រកួតប្រជែកគ្នាបាន
- ☐ កន្ត្រកដែលមានបិទក្រដាសធុងសំរាមទាំង៥នោះរើសយកតែ៤បានហើយ ចែក១ក្រុម២ប្រភេទ ដាក់តំរៀបនៅខាងមុខ ម្នាងដាក់២ ។
- ☐ កន្ត្រកធំមួយទៀត ដាក់ចំកណ្ដាល និងទុកដាក់សំរាម មួយប្រភេទ ចំនួន៥មុខ។ ដូច្នេះ ក្នុងកន្ត្រកហ្នឹងមានសំរាមចំនួន២០មុខ។
- ☐ ក្នុងក្រុម១ ត្រូវឱ្យកុមារម្នាក់ឡើងទៅលេងមុន ម្ដងមួយគូរៗ។ ក្រុមទី១ ១នាក់ និងក្រុមទី២ ១នាក់។
- ☐ ពួកគេត្រូវប្រកួតគ្នា រើសសំរាម ទៅដាក់នៅក្នុងធុងសំរាមដែលជារបស់ក្រុមពួកគេ ដែលមានពីរប្រភេទនៅខាងមុខនោះ
- ☐ ដាក់យ៉ាងមិច កុំឱ្យខុស ប្រភេទសំរាម នៅក្នុងធុងសំរាមរបស់ខ្លួននោះ
- ☐ សមាជិកក្រុមនៅកន្លែង អាចប្រាប់គ្នាបាន
- ☐ នៅពេលដែលដាក់អស់ គ្រូត្រូវរាប់សំរាមក្នុងធុង ទាំងពីររបស់ក្រុមទាំងពីរ និងគ្រូត្រូវពិនិត្យមើល ថាក្រុមនីមួយៗដាក់ត្រូវដែរឬអត់?
- ☐ ក្រុមណាដែលដាក់ត្រូវបានច្រើនជាងគេ គឺក្លាយជាអ្នកឈ្នះ សម្រាប់គូទី១។
- ☐ បន្ទាប់មក ចាប់ផ្ដើមគូទី២បន្តទៀត។ ធ្វើបែបហ្នឹងរហូតដល់អស់សមាជិកក្នុងក្រុមនីមួយៗ និងតាមពេលវេលាដែលមានសម្រាប់លេងផងដែរ។

4. នៅពេលដែលលេងរួច ប្រាប់ឱ្យកុមារទាំងអស់ជួយរៀបចំសម្ភារផង ប៉ុណ្ណឹងជាការស្រេច។

**ការប្រែប្រួលៈ**

ល្បែងអាចលេងបានម្យ៉ាងទៀតបាន ដូចនេះ

1. ចែកកុមារជាពីរក្រុមដដែល
2. លេងដូចគ្នាជាមួយហ្នឹងរបៀបទៅមួយទាំងអស់ តែកន្លែងដែលឱ្យកុមារឡើងទៅលេងតែ២នាក់ម្ដងនោះ យើងអាចលេង ក្នុងមួយក្រុមអាចលេងទាំងអស់ម្ដងបាន

3. គ្រាន់តែកុមារ១នាក់អាចរើសសំរាមទៅដាក់ក្នុងធុងដែលត្រឹមត្រូវនោះ យកបាតែ១ទេ កុមារឡើងជាបន្តបន្ទាប់គ្នា រហូតដល់អស់សំរាមក្នុងកន្ត្រក
4. គ្រូត្រូវត្រួតពិនិត្យ ពេលដែលកុមារបានរើសសំរាមរួចនោះ
5. ក្រុមណាដែលដាក់បានត្រឹមត្រូវច្រើនជាងគេ នឹងក្លាយជាក្រុមដែលឈ្នះតែម្តង។